អាជ្ញាធរមីន

C.M.A.A

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

# របាយការណ៍
# ស្តីពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
# នៅខែមេសា ឆ្នាំ២០២៤

## សាវតារ

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (CMVIS) បានបង្កើតឡើងនៅឆ្នាំ១៩៩៤ ដោយកាកបាទក្រហមកម្ពុជា ដែលគាំទ្រថវិកា ព្រមទាំងបច្ចេកទេសពីអង្គការជនពិការអន្តរជាតិបែលហ្ស៊ិក និងអង្គការយូនីសេហ្វ។

នៅដំណាច់ឆ្នាំ២០០៩ CMVIS ត្រូវបានផ្ទេរប្រគល់ពីកាកបាទក្រហមកម្ពុជា មកស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ក្នុងការប្រមូលទិន្នន័យ វិភាគទិន្នន័យ បកស្រាយទិន្នន័យ និងការចែកចាយទិន្នន័យជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.) នៅក្នុងប្រទេសកម្ពុជា។

## ព័ត៌មានស្តីពីគ្រោះថ្នាក់ និងជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (មីន និងស.ផ.ស.)

### ១-ជនរងគ្រោះពីខែមករា ឆ្នាំ១៩៧៩ ដល់ខែមេសា ឆ្នាំ២០២៤

ចាប់ពីខែមករា ឆ្នាំ១៩៧៩ ដល់ខែមេសា ឆ្នាំ២០២៤ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៦៥.០៦០នាក់ ដែលបានកត់ត្រាដោយការិយាល័យ CMVIS ក្នុងនោះរួមមាន៖

- ជនរងគ្រោះដោយសារមីន ៥១.១៩៥នាក់(៧៩%) និងស.ផ.ស. ១៣.៨៦៥នាក់(២១%)
- ជនរងគ្រោះស្លាប់ ១៩.៨២៨នាក់(៣០%) របួស ៣៦.១៤០នាក់(៥៦%) និងពិការអវយវៈ ៩.០៩២នាក់(១៤%)
- ជនរងគ្រោះជាបុរស ៥២.៦៨៦នាក់(៨១%) ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៦.១១៩នាក់(៩%) ស្ត្រី ៤.៧៩៦នាក់(៨%) ក្មេងស្រីអាយុក្រោម១៨ឆ្នាំ ១.៣៩៦នាក់(២%) និងជនរងគ្រោះមិនស្គាល់អត្តសញ្ញាណ ៦៣នាក់(0%)

### ២- ឧប្បត្តិហេតុគ្រោះថ្នាក់ពីខែមករា ដល់ខែមេសា ឆ្នាំ២០២៤

ចាប់ពីខែមករា ដល់ខែមេសា ឆ្នាំ២០២៤ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ១២ករណី។ តួលេខនេះដូចគ្នានឹងរយៈពេលដូចគ្នានៅឆ្នាំ២០២៣ ដែលមានឧប្បត្តិហេតុគ្រោះថ្នាក់ចំនួន ១២ករណី។

ក្នុងចំណោមឧប្បត្តិហេតុគ្រោះថ្នាក់ចំនួន ១២ករណីរួមមាន៖ ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន ៧ករណី និងឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារស.ផ.ស. ៥ករណី។

### ៣- ជនរងគ្រោះពីខែមករា ដល់ខែមេសា ឆ្នាំ២០២៤

ចាប់ពីខែមករា ដល់ខែមេសា ឆ្នាំ២០២៤ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ២៣នាក់។ តួលេខនេះបានកើនឡើង ៩២% បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២៣ ដែលមានជនរងគ្រោះចំនួន ១២នាក់។

ក្នុងចំណោមជនរងគ្រោះចំនួន ២៣នាក់ រួមមាន៖

- ជនរងគ្រោះដោយសារមីន ១១នាក់ និងជនរងគ្រោះដោយសារស.ផ.ស. ១២នាក់
- ជនរងគ្រោះស្លាប់ ៦នាក់ របួស ១៣នាក់ និងពិការអវយវៈ ៤នាក់
- ជនរងគ្រោះជាបុរស ១១នាក់ ជាក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៧នាក់ ស្ត្រី ២នាក់ និងជាក្មេងស្រីអាយុក្រោម១៨ឆ្នាំ ៣នាក់។

## ៤- ឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងខែមេសា ឆ្នាំ២០២៤

នៅខែមេសា ឆ្នាំ២០២៤ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៤ករណី បានកើតឡើងនៅខេត្តមណ្ឌលគិរី ខេត្តឧត្តរមានជ័យ ខេត្តព្រះសីហនុ និងខេត្តកំពង់ធំ។ តួលេខនេះកើនឡើង ១០០% បើប្រៀបធៀបនឹងខែមេសា ឆ្នាំ២០២៣។

ព័ត៌មានអំពីឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនៅខែមេសា ឆ្នាំ២០២៤

- ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន ១ករណី និងដោយសារស.ផ.ស. ៣ករណី
- ទីតាំងគ្រោះថ្នាក់កើតឡើងនៅតំបន់ផ្តល់អនុផលព្រៃឈើ ២ករណី និងនៅដីលំនៅដ្ឋាន ២ករណី។

## ៥- ជនរងគ្រោះក្នុងខែមេសា ឆ្នាំ២០២៤

នៅខែមេសា ឆ្នាំ២០២៤ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ១២នាក់។ តួលេខនេះបានកើនឡើង ១០០% បើប្រៀបធៀបនឹងខែមេសា ឆ្នាំ២០២៣។

ព័ត៌មានអំពីជនរងគ្រោះចំនួន ១២នាក់ រួមមាន៖

- ជនរងគ្រោះដោយសារមីន ១នាក់ និងជនរងគ្រោះដោយសារស.ផ.ស. ១១នាក់
- ជនរងគ្រោះស្លាប់ ៥នាក់ របួស ៦នាក់ និងពិការអវយវៈ ១នាក់
- ជនរងគ្រោះជាបុរស ៣នាក់ ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៥នាក់ ស្ត្រី ២នាក់ និងក្មេងស្រីអាយុក្រោម១៨ឆ្នាំ ២នាក់។
- សកម្មភាពនៅពេលគ្រោះថ្នាក់គឺ៖ ការរកស្បៀងអាហារ ១នាក់ ការលេងគ្រាប់ ៣នាក់ និងការរងគ្រោះពីអ្នកដទៃ ៨នាក់។

## ៦- ផលប៉ះពាល់នៃតំបន់គ្រោះថ្នាក់ពីខែមករា ឆ្នាំ២០២៣ ដល់ខែមេសា ឆ្នាំ២០២៤ (ជនរងគ្រោះ ៥៥នាក់)

- ខេត្តចំនួន ៥ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៦៥% នៃជនរងគ្រោះសរុប
- ស្រុកចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៧១% នៃជនរងគ្រោះសរុប
- ឃុំចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៦២% នៃជនរងគ្រោះសរុប។

*ព័ត៌មានលម្អិត សូមមើលទំព័រទី៧*

ប្រព័ន្ធពត៌មានជនរងគ្រោះដោយសារមីន នៅ កម្ពុជា




ព័ត៌មានលម្អិតទាក់ទងនឹងព័ត៌មានអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ សូមទំនាក់ទំនងមកការិយាល័យ CMVIS តាមរយៈអាសយដ្ឋានអ៊ីម៉ែល: ketya@cmaa.gov.kh

# របាយការណ៍ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះពីខែមករា ឆ្នាំ2021 ដល់ខែមេសា ឆ្នាំ2024

| | ជនរងគ្រោះតាមខែ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ/ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
| **2021** | **6** | **5** | **2** | **8** | **5** | **0** | **4** | **3** | **1** | **8** | **0** | **2** | **44** |
| *ការបូកបណ្តាក់ ឆ្នាំ2021* | *6* | *11* | *13* | *21* | *26* | *26* | *30* | *33* | *34* | *42* | *42* | *44* | |
| **2022** | **11** | **9** | **7** | **7** | **5** | **1** | **0** | **0** | **0** | **0** | **0** | **1** | **41** |
| *ការបូកបណ្តាក់ ឆ្នាំ2022* | 11 | 20 | 27 | 34 | 39 | 40 | 40 | 40 | 40 | 40 | 40 | 41 | |
| *ការប្រែប្រួលភាគរយ 2021 ធៀប 2022* | 83 | 82 | 108 | 62 | 50 | 54 | 33 | 21 | 18 | -5 | -5 | -7 | |
| **2023** | **3** | **5** | **4** | **0** | **7** | **2** | **2** | **3** | **1** | **2** | **1** | **2** | **32** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2022* | -8 | -4 | -3 | -7 | 2 | 1 | 2 | 3 | 1 | 2 | 1 | 1 | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2022* | -73 | -44 | -43 | -100 | 40 | 100 | 100 | 100 | 100 | 100 | 100 | 100 | |
| *ការបូកបណ្តាក់ ឆ្នាំ2023* | ***3*** | ***8*** | ***12*** | ***12*** | ***19*** | ***21*** | ***23*** | ***26*** | ***27*** | ***29*** | ***30*** | ***32*** | |
| *ការប្រែប្រួលភាគរយ 2022 ធៀប 2023* | -73 | -60 | -56 | -65 | -51 | -48 | -43 | -35 | -33 | -28 | -25 | -22 | |
| **2024** | **3** | **3** | **5** | **12** | | | | | | | | | **23** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2023* | 0 | -2 | 1 | 12 | | | | | | | | | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2023* | 0 | -40 | 25 | 100 | | | | | | | | | |
| *ការបូកបណ្តាក់ ឆ្នាំ2024* | ***3*** | 6 | ***11*** | ***23*** | | | | | | | | | |
| *ការប្រែប្រួលភាគរយ 2023 ធៀប 2024* | 0 | -25 | -8 | 92 | | | | | | | | | |

ចំណាំៈ តួលេខជនរងគ្រោះសម្រាប់ខែបន្តបន្ទាប់ទៀត នៃដំណើរការប្រមូលទិន្នន័យនឹងស្រាវជ្រាវឱ្យទាន់ពេលវេលា



## ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ចាប់ពីខែមករា ឆ្នាំ2023 ដល់ខែមេសា ឆ្នាំ2024

### រាជធានីខេត្តត្រូវបានតម្រៀបតាមលំដាប់ចុះនៃផលបូកសរុបជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងឆ្នាំ2023 និងឆ្នាំ2024

| | មករា23 | កុម្ភៈ23 | មីនា23 | មេសា23 | ឧសភា23 | មិថុនា23 | កក្កដា23 | សីហា23 | កញ្ញា23 | តុលា23 | វិច្ឆិកា 23 | ធ្នូ23 | សរុប2023 | មករា24 | កុម្ភៈ24 | មីនា24 | មេសា24 | ឧសភា24 | មិថុនា24 | កក្កដា24 | សីហា24 | កញ្ញា24 | តុលា24 | វិច្ឆិកា 24 | ធ្នូ24 | សរុប2024 | សរុប | ការបូកបណ្ដាក់លើសរុប | ភាគរយនៃសរុប | ការបូកបណ្ដាក់លើភាគរយសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះខេត្ត | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | **2023-2024** | | | |
| បាត់ដំបង | 0 | 0 | 0 | 0 | 2 | 0 | 0 | 1 | 1 | 0 | 0 | 2 | **6** | 0 | 1 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **3** | **9** | 9 | 16.4 | 16 |
| ឧត្តរមានជ័យ | 0 | 1 | 1 | 0 | 1 | 0 | 0 | 1 | 0 | 0 | 1 | 0 | **5** | 0 | 0 | 3 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **4** | **9** | 18 | 16.4 | 33 |
| បន្ទាយមានជ័យ | 0 | 0 | 0 | 0 | 3 | 0 | 1 | 0 | 0 | 1 | 0 | 0 | **5** | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | **7** | 25 | 12.7 | 45 |
| មណ្ឌលគិរី | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 6 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **6** | **6** | 31 | 10.9 | 56 |
| កំពង់ធំ | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **4** | **5** | 36 | 9.1 | 65 |
| រតនគិរី | 0 | 3 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | **4** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **4** | 40 | 7.3 | 73 |
| ពោធិ៍សាត់ | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 3 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **3** | **4** | 44 | 7.3 | 80 |
| ត្បូងឃ្មុំ | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | 0 | 1 | 0 | 0 | **3** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **3** | 47 | 5.5 | 85 |
| សៀមរាប | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **2** | 49 | 3.6 | 89 |
| ព្រះវិហារ | 1 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | **2** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **2** | 51 | 3.6 | 93 |
| កំពង់ឆ្នាំង | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **1** | 52 | 1.8 | 95 |
| តាកែវ | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **1** | 53 | 1.8 | 96 |
| ក្រចេះ | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **1** | 54 | 1.8 | 98 |
| ព្រះសីហនុ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **1** | 55 | 1.8 | 100 |
| កំពត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 55 | 0 | 100 |
| កំពង់ស្ពឺ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 55 | 0 | 100 |
| កំពង់ចាម | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 55 | 0 | 100 |
| កណ្ដាល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 55 | 0 | 100 |
| កោះកុង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 55 | 0 | 100 |
| ព្រៃវែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 55 | 0 | 100 |
| ស្ទឹងត្រែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 55 | 0 | 100 |
| ស្វាយរៀង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 55 | 0 | 100 |
| កែប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 55 | 0 | 100 |
| ប៉ៃលិន | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 55 | 0 | 100 |
| ភ្នំពេញ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 55 | 0 | 100 |
| **សរុប** | 3 | 5 | 4 | 0 | 7 | 2 | 2 | 3 | 1 | 2 | 1 | 2 | **32** | 3 | 3 | 5 | 12 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **23** | **55** | | | |



ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន នៅ កម្ពុជា

## ខេត្តចំនួន 5 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា ឆ្នាំ2023 ដល់ខែមេសា ឆ្នាំ2024

| លំដាប់ | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្ដាក់ លើផលបូកសរុប |
|---|---|---|---|---|---|
| 1 | បាត់ដំបង | 7 | 2 | **9** | 9 |
| 2 | ឧត្ដរមានជ័យ | 8 | 1 | **9** | 18 |
| 3 | បន្ទាយមានជ័យ | 6 | 1 | **7** | 25 |
| 4 | មណ្ឌលគិរី | 0 | 6 | **6** | 31 |
| 5 | កំពង់ធំ | 0 | 5 | **5** | 36 |

## ស្រុកចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា ឆ្នាំ2023 ដល់ខែមេសា ឆ្នាំ2024

| លំដាប់ | ស្រុក | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្ដាក់ លើផលបូកសរុប |
|---|---|---|---|---|---|---|
| 1 | សែនមនោរម្យ | មណ្ឌលគិរី | 0 | 6 | **6** | 6 |
| 2 | អន្លង់វែង | ឧត្ដរមានជ័យ | 5 | 1 | **6** | 12 |
| 3 | សំឡូត | បាត់ដំបង | 5 | 0 | **5** | 17 |
| 4 | ស្ទោង | កំពង់ធំ | 0 | 4 | **4** | 21 |
| 5 | វាលវែង | ពោធិ៍សាត់ | 4 | 0 | **4** | 25 |
| 6 | អូរយ៉ាដាវ | រតនគិរី | 1 | 3 | **4** | 29 |
| 7 | ថ្មពួក | បន្ទាយមានជ័យ | 3 | 0 | **3** | 32 |
| 8 | អូរជ្រៅ | បន្ទាយមានជ័យ | 3 | 0 | **3** | 35 |
| 9 | រតនៈមណ្ឌល | បាត់ដំបង | 1 | 1 | **2** | 37 |
| 10 | ជាំក្សាន្ត | ព្រះវិហារ | 2 | 0 | **2** | 39 |

## ឃុំចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា ឆ្នាំ2023 ដល់ខែមេសា ឆ្នាំ2024

| លំដាប់ | ឃុំ | ស្រុក | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្ដាក់ លើផលបូកសរុប |
|---|---|---|---|---|---|---|---|
| 1 | ត្រពាំងប្រិយ៍ | អន្លង់វែង | ឧត្ដរមានជ័យ | 5 | 1 | **6** | 6 |
| 2 | រមនា | សែនមនោរម្យ | មណ្ឌលគិរី | 0 | 6 | **6** | 12 |
| 3 | រុងរឿង | ស្ទោង | កំពង់ធំ | 0 | 4 | **4** | 16 |
| 4 | យ៉ាទុង | អូរយ៉ាដាវ | រតនគិរី | 0 | 3 | **3** | 19 |
| 5 | អូរបីជាន់ | អូរជ្រៅ | បន្ទាយមានជ័យ | 3 | 0 | **3** | 22 |
| 6 | គោករមៀត | ថ្មពួក | បន្ទាយមានជ័យ | 3 | 0 | **3** | 25 |
| 7 | ថ្មដា | វាលវែង | ពោធិ៍សាត់ | 3 | 0 | **3** | 28 |
| 8 | តាតោក | សំឡូត | បាត់ដំបង | 2 | 0 | **2** | 30 |
| 9 | រុនតាឯក | បន្ទាយស្រី | សៀមរាប | 0 | 2 | **2** | 32 |
| 10 | គោកស្រុក | តំបែរ | ត្បូងឃ្មុំ | 0 | 2 | **2** | 34 |

# ការផ្ទុះបញ្ចាំងទូទៅលើជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

អំឡុងពេលៈ មករា ឆ្នាំ2023 - មេសា ឆ្នាំ2024

ចំនួនសរុបនៃជនរងគ្រោះក្នុងអំឡុងពេលរាយការណ៍: 55










## ការផ្ទុះបញ្ចាំងទូទៅលើករណីរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ












ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន នៅ កម្ពុជា

អំឡុងពេលៈ ខែមករា ឆ្នាំ2023 - ខែមេសា ឆ្នាំ2024

ចំនួនសរុបនៃជនរងគ្រោះ ក្នុងអំឡុងពេលរាយការណ៍ៈ 55

## សកម្មភាពដែលបណ្តាលឱ្យគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ បែងចែកទៅតាមប្រភេទជនរងគ្រោះ

| បុរស | ស្ត្រី | ក្មេង | សរុប |
|---|---|---|---|
| 36 | 3 | 16 | 55 |




## សកម្មភាពរបស់ជនរងគ្រោះនៅពេលដែលគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

### សកម្មភាពដែលបណ្តាលឱ្យផ្ទុះមីន

28




### សកម្មភាពដែលបណ្តាលឱ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម

27




## ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមលក្ខណៈភូមិសាស្ត្រដី

### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឱ្យផ្ទុះមីន




### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឱ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម

